ព្រឹត្តិបត្រព័ត៌មាន

# គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ

# NGO Committee on the Rights of the Child

# NGOCRC

ឆ្នាំទី៤លេខ១៣ ខែមករា_មិនាឆ្នាំ២០០៧

មាតិកា ទំព័រ

កិច្ចប្រជុំពិភាក្សាអំពីធម្មនុញ្ញភាពនៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ....................................១

វេទិកាកុមារ ពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៏ការអនុវត្តន៏អនុសញ្ញាស្តីពីសិទ្ធិកុមារ.....................៣

សិក្ខាសាលាចែកចាយស្ថិតិរួមរបស់អង្គការនានា ស្តីពីការរំលោភ និងជួញដូរនៅឆ្នាំ ២០០៣-២០០៤.....................២

ទស្សនកិច្ចរបស់គណៈប្រតិភូភ្នាក់ងារអភិវឌ្ឍន៏អន្តរជាតិស៊ុយអែត...............៧

សិក្ខាសាលាស្តីពីការរៀបចំកម្មវិធីដោយផ្អែកលើសិទ្ធិជាមូលដ្ឋានរបស់កុមារ....................................៨

សេចក្តីថ្លែងការណ៏ស្តីពីស្ថានភាពកុមារ...៩

## កិច្ចប្រជុំពិភាក្សាអំពីធម្មនុញ្ញភាពនៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ



គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ សហការជាមួយអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា រៀបចំកិច្ចប្រជុំពិភាក្សាអំពីធម្មនុញ្ញភាពនៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងសំដែងនូវការព្រួយបារម្ភអំពីសិទ្ធិត្រឹមត្រូវតាមផ្លូវច្បាប់ និងសិទ្ធិផ្សេងៗទៀតរបស់កុមារ ដែលកំពុងប្រឈមមុខនឹងផ្លូវច្បាប់ ដោយមានតំណាងចូលរួមមកពីអង្គការមិនមែនរដ្ឋាភិបាល ជាតិ និងអន្តរជាតិដែលធ្វើការពាក់ព័ន្ធនឹងកុមារ អង្គការសិទ្ធិមនុស្ស អង្គការបំរើសេវាកម្មច្បាប់ដល់ជនក្រីក្រ វិទ្យាស្ថានគ្រប់គ្រងបូពា៌-បស្ចិម EWMI និងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស។

ក្រុមអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសិទ្ធិមនុស្ស យល់ឃើញថាច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ដែលបានប្រកាសអោយប្រើកាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ ២០០២ បានបង្កអោយមានផលប៉ះពាល់ជាច្រើនទៅលើកុមារ ដែលច្បាប់នេះបានលប់ចោលពីលទ្ធភាពរបស់ចៅក្រម ក្នុងការពិចារណាពីស្ថានសំរាល ដើម្បីបន្ថយ

តទៅទំព័រទី១១

# សិក្ខាសាលាចែកចាយស្ថិតិរួមរបស់អង្គការនានា ស្តីពីការរំលោភ និងជួញដូរនៅឆ្នាំ ២០០៣-២០០៤

សិក្ខាសាលាស្តីពីការចែកចាយស្ថិតិរួមរបស់ អង្គការនានា ស្តីពីការរំលោភ និងជួញដូរនៅឆ្នាំ២០០៣-២០០៤ ត្រូវបាន រៀបចំឡើងនៅព្រឹកថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០០៧ នៅសណ្ឋាគារ សាន់វេ ក្រោមកិច្ចសហការរៀបចំរវាង គណៈកម្មាធិការបំបាត់ ពេស្យាចារ ការរំលោភ និងជួញដូរកុមារនៅកម្ពុជា (អ៊ិកផាត កម្ពុជា) និងគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បី សិទ្ធិកុមារ ដោយទទួលបានជំនួយឧបត្ថម្ភថវិកា ពីអង្គការ **ANESVAD** ។ សិក្ខាសាលានេះ មានអ្នកចូលរួមមកពីស្ថាប័នរដ្ឋ ស្ថានទូត និងអង្គការមិនមែនរដ្ឋាភិបាល ជាតិ និងអន្តរជាតិនានា សរុបចំនួន ៤៦ នាក់ ។

លោក ជា ពីដែន អនុប្រធានក្រុមប្រឹក្សាភិបាលរបស់ គណៈកម្មាធិការអ៊ិកផាតកម្ពុជា មានប្រសាសន៍ក្នុងឱកាសបើក សិក្ខាសាលានោះថា កន្លងមកអង្គការក្រៅរដ្ឋាភិបាលនានាមាន ការលំបាកក្នុងការស្វែងរកទិន្នន័យដែលអាចជឿទុកចិត្តបាន ដោយសារថា អង្គការខ្លះធ្វើការប្រមូលគ្រប់គ្រងទិន្នន័យ ក្នុង ទ្រង់ទ្រាយតូច និងមិនបានចែកចាយអោយបានទូលំទូលាយ ហើយរបាយការណ៍ក្នុងថ្ងៃនេះ ជាលទ្ធផលនៃកិច្ចសហប្រតិបត្តិ-ការ របស់យើងទាំងអស់គ្នា ក្នុងការចងក្រងទិន្នន័យរួមស្តីពីការ រំលោភ និងជួញដូរក្នុងឆ្នាំ ២០០៣-២០០៤ ។ លោកបានបន្ត អំពាវនាវដល់ស្ថាប័នរដ្ឋាភិបាល អង្គការ និងស្ថាប័នដែលពាក់ព័ន្ធ ទាំងអស់ មេត្តាចូលរួម និងបន្តចូលរួមសហការក្នុងគម្រោង ប្រមូលទិន្នន័យនេះ ក្នុងដំណាក់កាលទី ២ និង ដំណាក់កាល ក្រោយៗទៀត ដើម្បីអោយយើងអាចមានទិន្នន័យគ្រប់គ្រាន់ សំរាប់វិភាគ និងតាមដានការប្រែប្រួលករណីនេះ ។

លោក ជិន ចាន់វាសនា នាយកប្រតិបត្តិគណៈ-កម្មាធិការអ៊ិកផាតកម្ពុជា បញ្ជាក់ថា គំរោងនេះមានគោល បំណងផ្តល់នូវ ការវិភាគលើស្ថិតិដែលអាចជឿទុកចិត្តបាន សំរាប់ករណីរំលោភសេពសន្ថវៈ និងជួញដូរមនុស្សដែលបាន រក្សាទុក (២០០៣ -២០០៤) ដើម្បីផ្តល់ជាព័ត៌មាន ដែលមាន សារៈសំខាន់សំរាប់ អង្គការមិនមែនរដ្ឋាភិបាល ក្នុងការរៀបចំ គំរោងទៅអនាគត និងផ្តល់នូវការកត់ត្រាត្រឹមត្រូវ ដើម្បី តាមដានពិនិត្យលើភាពជឿនលឿន និងការផ្លាស់ប្តូរនៅពេល ខាងមុខ និងសំរបសំរួលនូវកំណត់ត្រារបស់ អង្គការមិនមែន រដ្ឋាភិបាល ដើម្បីធានានូវរបាយការណ៍ដ៏ត្រឹមត្រូវ និងការចែក ចាយនូវព័ត៌មានសំខាន់ៗ និង ពង្រឹងនូវកិច្ចសហប្រតិបត្តិការ និងធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការធ្វើការ ទប់ស្កាត់ ករណីរំលោភសេពសន្ថវៈ និងជួញដូរមនុស្ស និងដើម្បីជួយជនរងគ្រោះ ។

លោកបានបន្តទៀតថាគម្រោងនេះកន្លងមកមានការ ចូលរួមសហការពីអង្គការជាតិនិងអន្តរជាតិ ចំនួន២២ ដែលក្នុង នោះភាគច្រើនជាសមាជិករបស់ បណ្តាញគណៈកម្មាធិការ អ៊ិកផាតកម្ពុជា និងបណ្តាញគណៈកម្មាធិការអង្គការមិនមែន រដ្ឋាភិបាលដើម្បីសិទ្ធិកុមារ ដែលរួមមានៈ អង្គការអាហ្វេស៊ីប (AFESIP) អង្គការកុមារកម្ពុជា(CoC) អង្គការភ្នាក់ងារ អភិវឌ្ឍន៍ស្ត្រីកម្ពុជា(CWDA) អង្គការគាំពារកុមារដែលងាយ ទទួលរងគ្រោះ(VCAO) អង្គការហាការ(Hagar) មជ្ឈមណ្ឌល ថែទាំសុខភាពកុមារ(HCC) អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) អង្គការការពារយុត្តិធម៌កុមារ(PJJ) អង្គការទស្សនៈ ពិភពលោកកម្ពុជា(WVC) សមាគមកុមារកម្ពុជាប្រឆាំង ទុរភិក្ស និងហិង្សា(CCASVA) មជ្ឈមណ្ឌលកម្ពុជា

តទៅទំព័រទី5

# វេទិកាកុមារ ពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍ ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ



ឯកឧត្តមអ៊ិត សំហេង និងក្រុមកុមារតស៊ូមតិ

វេទិកាកុមារបានប្រមូលផ្តុំតំណាងកុមារ ដែលមានអាយុពី១៤-១៧ឆ្នាំ ចំនួន២៦នាក់មក ពីខេត្ត/ក្រុង ចំនួន៨ (ប៉ោយប៉ែត-ខេត្តបន្ទាយមានជ័យ រតនះគីរី សៀមរាប ពោធិ៍សាត់ កំពង់ចាម តាកែវ ក្រុងព្រះសីហនុ និងក្រុងភ្នំពេញ) ដើម្បីជជែកពិភាក្សា និងផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍លើកទី២ និងទី៣របស់រដ្ឋាភិបាល ស្តីពីការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ នៅកម្ពុជា ឆ្នាំ២០០០-២០០៦។ វេទិកានេះត្រូវបានដឹកនាំ និងសម្របសម្រួលដោយតំណាងកុមារ និងយុវជនវ័យក្មេងមកពី គណៈកម្មាធិការកុមារអង្គការជំនួយកុមារដើម្បីការរួបរួម និងការចូលរួម និងបណ្តាញកុមារអ្នកតស៊ូមតិនៃគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ។

វេទិកាកុមារនេះត្រូវបានសហការរៀបចំឡើង ដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.ក) និងគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ កាលពីថ្ងៃទី២៥-២៦ ខែកុម្ភៈ ឆ្នាំ២០០៧ នៅសាលប្រជុំទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

លោកស្រី ច័ន្ទ ហារ៉ានវដ្តី អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មានប្រសាសន៍ថា វេទិកាកុមារក្នុងពេលនេះ មានគោលបំណងអោយក្មួយៗកុមារ មានឱកាសផ្តល់មតិយោបល់ពិនិត្យលើរបាយការណ៍ស្តីពីការអនុវត្តសិទ្ធិកុមារ ដោយពិនិត្យ មើលទៅលើចំណុចខ្វះខាត ការបារម្ភរបស់កុមារលើបញ្ហានានា និងលើកឡើងជាអនុសាសន៍ដើម្បីអោយ ក.ជ.ក.ក លើកយកទៅពិចារណា និងរៀបចំដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងរបាយការណ៍។ លោកស្រីបន្តទៀតថា ក.ជ.ក.ក ជាស្ថាប័ន អន្តរក្រសួងដែលមានសម្តេចនាយករដ្ឋមន្ត្រីជាប្រធានកិត្តិយស ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ជាប្រធាន និងឯកឧត្តម លោកជំទាវតំណាងស្ថាប័នចំនួន១៨ទៀត ជាអនុប្រធាន និងជាសមាជិក។ ក្រុមប្រឹក្សានេះមានតួនាទីៈ ១-សម្របសម្រួលជំរុញការអនុវត្តន៏អនុសញ្ញាស្តីពីសិទ្ធិកុមារ ២-ធ្វើការត្រួតពិនិត្យតាមដានលើសកម្មភាព និងកម្មវិធីទាំងឡាយ ដែលទាំងស្ថាប័នរដ្ឋាភិបាលក៏ដូចជាស្ថាប័នអង្គការមិនមែនរដ្ឋាភិបាល បាន និងកំពុងអនុវត្តន៏នៅប្រទេសកម្ពុជា ៣-ផ្សព្វផ្សាយទាក់ទាញមតិគាំទ្រពាក់ព័ន្ធនឹងសិទ្ធិកុមារ ៤-ជាសេនាធិការរបស់រដ្ឋាភិបាលក្នុងការរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីស្ថានភាពកុមារ ដើម្បីដាក់ជូនអង្គការសហប្រជាជាតិ។

លោកស្រី អាសាកូ តំណាងអង្គការយូនីសេហ្វ បានមានប្រសាសន៏ថា វេទិកាកុមារក្នុងថ្ងៃនេះ ផ្តល់ឱកាសអោយប្អូនៗកុមារ បានចូលរួមបញ្ចេញមតិទស្សនៈ ទៅលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា ដែលគំនិត និងទស្សនៈរបស់ប្អូនៗកុមារ នឹងត្រូវដាក់បញ្ចូលទៅក្នុង សេចក្តីព្រាងរបាយការណ៍

តទៅទំព័រទី៤

តមកពីទំព័រទី៣

ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលនឹងដាក់ជូនគណៈកម្មា-ធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ ។

ឯកឧត្តម អ៊ិត សំហេង ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងជារដ្ឋមន្ត្រីក្រសួង សង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងឱកាសបិទវេទិកាកុមារ បានសំដែងនូវក្តីសប្បាយរីករាយ និងថ្លែងអំណរគុណដល់អង្គការយូនីសេហ្វ ដែលបានឧបត្ថម្ភអោយមានវេទិកានេះឡើង។ ឯកឧត្តម សូមស្វាគមន៏យ៉ាងកក់ក្តៅចំពោះរាល់មតិយោបល់និងអនុសាសន៏ទាំងឡាយដែលជាលទ្ធផលនៃវេទិកានេះ។ ឯកឧត្តម បន្តទៀតថា តាងនាមអោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ឯកឧត្តម មានការសប្បាយរីករាយក្នុងការស្តាប់មតិយោបល់ របស់ក្មួយៗកុមារ ហើយមតិយោបល់ទាំងនេះ ឆ្លុះបញ្ចាំងពីស្ថានភាពពិតជាក់ស្តែង របស់កុមារនៅប្រទេសកម្ពុជា។ ឯកឧត្តម ស្វាគមន៏ និងទទួលយកអនុសាសន៏ដែលបានលើកឡើងទាំងអស់ ទៅធ្វើការឆ្លុះបញ្ចាំងនិងរៀបចំបញ្ចូលក្នុងរបាយការណ៏ជាតិ។

ឯកឧត្តមបានថ្លែងអំណរគុណចំពោះអ្នកសម្របសម្រួលជាក្រុមកុមារ និងយុវជន ដែលបានជួយគាំទ្រ ដឹកនាំអោយក្មួយៗកុមារអាចបញ្ចេញមតិយោបល់ទាំងនោះបាន។

ខាងក្រោមនេះជាលទ្ធផលនៃអង្គវេទិកាដែលរាយការណ៏ជូនដោយតំណាងកុមារទៅកាន់ឯកឧត្តម ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងសមាជិក សមាជិកា នៃក្រុមប្រឹក្សានេះ ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងតំណាងក្រសួងស្ថាប័នចំនួន១៨។ ការពិភាក្សានិងរាយការណ៏ផ្អែកទៅលើប្រធានបទចំនួន៤ យោងទៅតាមការណែនាំក្នុងការធ្វើរបាយការណ៏សំរាប់រដ្ឋជាភាគី។

**១-<u>ក្រុមទី ១ : សិទ្ធិ និងសេរីភាព ការអប់រំ ការលំហែ និងសកម្មភាពវប្បធម៌</u>**

**<u>ការចូលរួម</u> :**

*<u>ចំណុចខ្វះខាត</u>* :

-ទិវា ១ មិថុនា មិនទាន់បានរៀបចំនៅគ្រប់ខេត្តក្រុងនៅឡើយ

-ចំនួននៃការចូលរួមរបស់កុមារនៅមានកំរិតទាប

-មិនទាន់មានកញ្ចប់ថវិកាជាតិសំរាប់គាំទ្រគំនិតផ្តួចផ្តើម និងសកម្មភាពគាំទ្រដោយកុមារ

-មិនទាន់មានតំណាងកុមារចូលរួមក្នុងការធ្វើផែនការអភិវឌ្ឍឃុំសង្កាត់

-កម្មវិធីសាលាមេត្រីមិនទាន់ត្រូវបានអនុវត្ត និងមិនទាន់មានអ្នកយល់ដឹងស្គាល់

-ដំណើរការកែទំរង់ប្រព័ន្ធអប់រំនៅមានសន្ទុះយឺត

-ការផ្តល់អាហារូបករណ៏ដល់កុមារក្រីក្រមិនទាន់បានគ្រប់គ្រាន់

-មិនទាន់មានបណ្តាញកុមារថ្នាក់ជាតិ និងគ្រប់លំដាប់ថ្នាក់

-ពុំទាន់មានការជួយឧបត្ថម្ភ និងគាំទ្រគ្រប់គ្រាន់ដល់ការបង្កើតអោយមានក្រុមបណ្តាញកុមារគ្រប់ខេត្ត-ក្រុង

-ការផ្សព្វផ្សាយពីសារៈសំខាន់នៃការចូលរួមរបស់កុមារមិនទាន់បានទូលំទូលាយ

-វេទិកាជាតិទាក់ទងនឹងពលកម្មកុមារមិនទាន់បានបញ្ចូលអោយមានការចូលរួមពីកុមារនៅឡើយ

*<u>អនុសាសន៏</u>* :

-បង្កើតយុទ្ធនាការផ្សព្វផ្សាយសិទ្ធិកុមារតាមបណ្តាខេត្តដាច់ស្រយាល ដោយមានការចូលរួមពីកុមារអោយបានច្រើន (ពិសេសកុមារដែលមានបទពិសោធន៏)

-បង្កើតអោយមានវេទិកាកុមារថ្នាក់ជាតិទាក់ទងពលកម្មកុមារដោយមានការចូលរួមពីកុមារ

-បង្កើតអោយមានវេទិកាថ្នាក់ជាតិស្តីពីការចូលរួមរបស់កុមារ

តទៅទំព័រទី៥

តមកពីទំព័រទី៤


កិច្ចពិភាក្សារបស់ក្រុមកុមារលើប្រធានបទៈ ការអប់រំ

-ពង្រឹងបន្ថែមអោយមានការផ្សព្វផ្សាយពីសិទ្ធិកុមារ ដោយមានការចូលរួមពីកុមារក្នុងគ្រប់ប្រព័ន្ធផ្សព្វផ្សាយ

-បង្កើតអោយមានទិវាកុមារអន្តរជាតិ ១ មិថុនា នៅគ្រប់ខេត្ត

-ជំរុញអោយកុមារជនជាតិភាគតិចចូលរួមអោយបានកាន់តែច្រើនចំពោះរាល់សកម្មភាពដែលទាក់ទងនឹងកុមារ

-បង្កើតកញ្ចប់ថវិការបស់រដ្ឋាភិបាលសំរាប់សកម្មភាពចូលរួម និងគាំទ្រគំនិតផ្តួចផ្តើមរបស់កុមារ

-ចង់អោយតំណាងកុមារចូលរួមក្នុងការធ្វើផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់

-ជួយឧបត្ថម្ភ និងគាំទ្រដល់ការបង្កើតអោយមានក្រុម និងបណ្តាញកុមារថ្នាក់ជាតិ រហូតដល់ថ្នាក់មូលដ្ឋាន

-ពង្រីកការផ្សព្វផ្សាយពីសិទ្ធិកុមារតាមគ្រប់ប្រព័ន្ធផ្សព្វផ្សាយ ដោយមានការចូលរួមពីកុមារ

-សុំអោយដាក់ថ្ងៃ ១ មិថុនា ជាថ្ងៃឈប់សំរាកជាតិ

-សូមអោយកុមារ និងយុវជនចូលរួមរាល់សកម្មភាព ឬកិច្ចប្រជុំដែលទាក់ទងនឹងកុមារ

**<u>ការអប់រំ</u> :**

*<u>ចំណុចខ្វះខាត</u> :*

១-<u>គ្រូបង្រៀន</u>

-គ្រូបង្រៀនមានចំនួនតិច

-ដាក់គ្រូខុសមុខជំនាញ

-គ្រូមួយចំនួនតូចខ្វះគរុកោសល្យបង្រៀន

-ប្រាក់ខែគ្រូបង្រៀនតិច និងបើកប្រាក់ខែមិនទៀងទាត់

-គ្រូមួយចំនួនចូលចិត្តប្រមូលលុយសិស្ស ឬលក់របស់របរ ឯកសារដើម្បីប្រមូលលុយពីសិស្ស

-គ្រូមួយចំនួនអត់យកចិត្តទុកដាក់អំពីគុណភាពនៃការអប់រំ

-គ្រូមួយចំនួនរើសអើងនិងលំអៀង

-គ្រូមួយចំនួនប្រើអំពើហិង្សាជាមួយសិស្ស

២-<u>សម្ភារៈ</u>

-ខ្វះឯកសារសំរាប់សិស្ស

-ខ្វះសំភារៈសិក្សា ( ឧបករណ៍ពិសោធន៍ តុ ទូ កៅអី ក្តាខៀន...)

-ខ្វះសំភារៈកីឡា

-ខ្វះសំភារៈកំសាន្ត និងកន្លែងកំសាន្តសំរាប់កុមារ

៣-<u>អាគារ</u>

-ខ្វះសាលារៀន

-សាលារៀននៅឆ្ងាយពីផ្ទះ ( តំបន់ដាច់ស្រយាល)

-ខ្វះអាគារស្នាក់នៅសំរាប់គ្រូបង្រៀន និងសិស្សមកពីឆ្ងាយ

-សាលាមត្តេយ្យមិនទាន់គ្រប់គ្រាន់

៤-<u>ការចុះឈ្មោះចូលរៀន</u>

-មានការកើនឡើង

-ការបោះបង់ចោលការសិក្សាមានចំនួនកើនឡើងដែរ

៥-<u>កម្មវិធីសិក្សា</u>

-ខ្វះសាលាកុមារមេត្រី

-ខ្វះកន្លែងស្នាក់នៅសំរាប់គ្រូ

តទៅទំព័រទី១២

តពីទំព័រទី២

ដើម្បីការពារសិទ្ធិកុមារ(CCPCR) អង្គការគ្រួសារថ្មី(KT)។ ក្រៅពីអង្គការជាសមាជិករបស់បណ្តាញអង្គការទាំងពីរ មានអង្គការ និងស្ថាប័នផ្សេងៗទៀតដែលបានចូលរួមសហការផ្តល់ព័ត៌មាន ផងដែរដូចជាៈ អង្គការសកម្មភាពដើម្បីកុមារ(APLE) អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(CWCC) អង្គការមាតុភូមិយើង(Homeland) អង្គការកុមាររីករាយ(KMR) គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា(BAKC) ៦-អង្គការអភិវឌ្ឍកុមារ និងជនពិការកម្ពុជា(CCHDO) អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា(CDP) អង្គការតំណក់ទឹក(Goutte D' Eau) ។

របាយការណ៍នេះ បានបង្ហាញអំពីការរកឃើញករណីរំលោភសេពសន្ថវៈមានចំនួន ៥៥៨ ករណី ដែលឆ្នាំ២០០៣មាន ៣១៨ករណី និងឆ្នាំ២០០៤មាន ២៤០ករណី យោងតាមទិន្នន័យដែលប្រមូលបានពី ២១ ខេត្ត-ក្រុង និងករណីជួញដូរមាន ៧៦១ ករណី (ឆ្នាំ២០០៣មាន ៣៩៣ករណី និងឆ្នាំ២០០៤មាន ៣៦៨ករណី) យោងតាមទិន្នន័យដែលប្រមូលបានពី ១០ ខេត្ត-ក្រុង។ ទោះបីជាមាននិន្នាការថយចុះក៏ដោយ គេសង្កេតឃើញថាករណីរំលោភត្រូវបានរាយការណ៍ថា មានការកើនឡើងនៅខេត្តបន្ទាយមានជ័យ និងប៉ៃលិន ចំណែកខេត្តកំពត និងកោះកុងនៅដដែល។ ហើយយើងមិនឃើញមានរបាយការណ៍មកពីខេត្តព្រះវិហារ និងស្ទឹងត្រែងទេ ។ ករណីរំលោភមានអំពើហិង្សាកាន់តែកើនឡើង តាមរយៈការកើនឡើងនូវចំនួនជនល្មើស និងការប្រើប្រាស់អាវុធ ។ កុមារីក្មេងៗជាគោលដៅនៃការរំលោភ ហើយមានការកើនឡើងនៅឆ្នាំ ២០០៤។ ភាគច្រើនករណីរំលោភត្រូវបានប្រព្រឹត្តឡើងដោយបុរសជនជាតិខ្មែរ (មានជនបរទេសតិចតួច) ហើយស្ត្រីជាអ្នកចូលដៃនៅក្នុងករណីខ្លះផងដែរ ។ ជនល្មើសមានគ្រប់វ័យ រួមទាំង មនុស្សចាស់ និងក្មេងប្រុស ដែលចំនួនជនប្រព្រឹត្តបទល្មើសជាកុមារាមានការកើនឡើងនៅឆ្នាំ ២០០៤។ ភាគច្រើននៃការរំលោភត្រូវបានប្រព្រឹត្តឡើងដោយអ្នកដែលស្គាល់គ្នាជាមួយជនរងគ្រោះ ដូចជាអ្នកជិតខាង មនុស្សដែលស្គាល់គ្នា និងសមាជិកក្នុងគ្រួសារ។

ចំណែកករណីជួញដូរវិញ ភាគច្រើនកើតនៅទីក្រុង និងតាមព្រំដែន។ គេសង្កេតឃើញថា ករណីជាច្រើនជាករណីជួញដូរក្នុងប្រទេស ហើយមានករណីមួយចំនួនត្រូវបានជួញដូរទៅប្រទេសថៃ និងម៉ាឡេស៊ី។ នៅឆ្នាំ ២០០៤ ប្រទេសមួយចំនួនដូចជា វៀតណាម និងចិនត្រូវបានគេកត់សំគាល់ថា ជាប្រទេសគោលដៅ បន្ថែមទៀតក្នុងការជួញដូរពីកម្ពុជា។ ទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងខេត្តសៀមរាប ជាគោលដៅចំបងនៅក្នុងប្រទេស។ ជនរងគ្រោះភាគច្រើនជាជនជាតិខ្មែរ និងមានខ្លះជាជនជាតិវៀតណាម ដែលភាគច្រើនជាកុមារក្រោមអាយុ ១៨ ឆ្នាំ រួមទាំងកុមារដែលមានអាយុពី ៩-១២ឆ្នាំ ។ ចំណែកជនល្មើសភាគច្រើនជាស្ត្រី។ ភាគច្រើននៃជនល្មើសមានជាប់ពាក់ព័ន្ធដោយផ្ទាល់ ឬប្រយោលទៅនឹងឧស្សាហកម្មផ្លូវភេទ។ គេសង្កេតឃើញមានប៉ូលីស និងមន្ត្រីរាជការខ្លះក៏ជាប់ពាក់ព័ន្ធនឹងបទល្មើសនេះផងដែរ ហើយជនល្មើសផ្សេងទៀតរួមមាន ម្ចាស់ហាងកាហ្វេ អ្នកបើកបរតាក់ស៊ី កម្មកររោងចក្រ អ្នកលក់អង្ករ កសិករ និងអ្នកនេសាទ ជាដើម ។ សមាជិកគ្រួសារដែលជាប់ពាក់ព័ន្ធក្នុងករណីជួញដូរត្រូវបានបង្ហាញថាមានការថយចុះ ។

ទោះបីជាមានលទ្ធផលក្នុងពេលនេះហើយក៏ដោយ លោក ជិន ច័ន្ទវាសនា តាងនាមអ៊ិកផាត និង គ.អ.ស.ក សូមអំពាវនាវដល់អង្គការនិងស្ថាប័នដែលពាក់ព័ន្ធទាំងអស់មេត្តាបន្តចូលរួមសហការផ្តល់យោបល់កែលំអ លើគម្រោង

តទៅទំព័រទី៧

តមកពីទំព័រទី៦

នេះលើកក្រោយៗ អោយកាន់តែល្អឡើង និងចូលរួមប្រមូលទិន្នន័យ និងផ្តល់ទិន្នន័យអោយបានលំអិត ទាក់ទងនឹងករណីនីមួយៗ។

លោក មាស សំណាង ប្រធានគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ ក្នុងឱកាសបិទអង្គសិក្ខាសាលា បានសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ វត្តមានរបស់អ្នកចូលរួមទាំងអស់ ដែលអញ្ជើញមកពីស្ថាប័នរាជរដ្ឋាភិបាល ស្ថានទូត ម្ចាស់មូលនិធិ និង អង្គការមិនមែនរដ្ឋាភិបាល ជាតិនិងអន្តរជាតិទាំងឡាយ ដែលបានចូលរួមសិក្ខាសាលាក្នុងព្រឹកនោះ។ លោកបន្តទៀតថា សិក្ខាសាលានេះ បានផ្តល់នូវព័ត៌មានដ៏មានតំលៃពាក់ពន្ធ័នឹងបទល្មើស នៃការជួញដូរនិងរំលោភសេពសន្ថវៈ សម្រាប់ជាមូលដ្ឋាន ដល់ស្ថាប័នដែលពាក់ព័ន្ធនានា ក្នុងការរៀបចំផែនការសកម្មភាព និងធ្វើសេចក្តីសំរេចចិត្ត។ មិនតែប៉ុណ្ណោះ របាយការណ៍ថ្ងៃនេះ ក៏បានឆ្លុះបញ្ចាំងពីលទ្ធផលនៃការខិតខំប្រឹងប្រែង របស់ស្ថាប័នពាក់ព័ន្ធទាំងអស់ក្នុងការលុបបំបាត់អំពើជួញដូរនិងរំលោភសេពសន្ថវៈ។ ហើយលោកសង្ឃឹមថា ឆន្ទៈនិងកិច្ចខិតខំប្រឹងប្រែងទាំងនេះ នឹងធ្វើអោយប្រទេសកម្ពុជាក្លាយជាប្រទេសរុងរឿងមួយ ដែលពុំមានករណីរំលោភនិងជួញដូរដ៏ច្រើនដូចសព្វថ្ងៃទៀតឡើយ នៅថ្ងៃអនាគត។

## ទស្សនកិច្ចរបស់គណៈប្រតិភូភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត



ក្នុងដំណើរទស្សនកិច្ចរយៈពេល ១ សប្តាហ៍របស់ខ្លួននៅប្រទេសកម្ពុជា នៅថ្ងៃអង្គារទី១៣ ខែមីនា ឆ្នាំ២០០៧ គណៈប្រតិភូមកពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែតចំនួន៣រូប និងអមដំណើរដោយលោក ព្រំ ថារី ទីប្រឹក្សាប្រចាំប្រទេស ផ្នែកសិទ្ធិកុមារ នៃអង្គការភ្លែនអន្តរជាតិ កម្ពុជា បានអញ្ជើញមកបំពេញទស្សនកិច្ចនៅ គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ ដើម្បីស្វែងយល់ពីសកម្មភាពការងារ និងលទ្ធផលដែល គ. អ. ស. ក បានសម្រេចបាន ក្នុងការអនុវត្តគំរោងតស៊ូមតិដើម្បីការចូលរួមរបស់កុមារ ដែលស្ថិតនៅក្រោមជំនួយឧបត្ថម្ភថវិការបស់អង្គការភ្លែន។

លោក មាស សំណាង និងសមាជិក សមាជិកាគណៈកម្មាធិការប្រតិបត្តិ ព្រមទាំងបុគ្គលិកទាំងអស់ បានជួបសំណេះសំណាលនិងសំដែងការគួរសមចំពោះប្រតិភូនៅរសៀលថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៧។ លោក មាស សំណាង បានជំរាបជូនត្រួសៗអំពីប្រវត្តិ ដំណើរការរៀបចំ និងការប្រព្រឹត្តទៅរបស់ គ.អ.ស.ក ព្រមទាំងស្ថានភាពទូទៅរបស់កុមារក្នុងប្រទេសកម្ពុជា ជូនដល់សមាជិកគណៈប្រតិភូ។

លោក ស៊ុំ ចំរុង អគ្គលេខាធិការ គ. អ. ស. ក បានបង្ហាញជូនគណៈប្រតិភូ អំពីដំណើរការរីកចំរើននៃការអនុវត្តគំរោងតស៊ូមតិដើម្បីការចូលរួមរបស់កុមារ។ រហូតមកទល់នឹងពេលនេះ គ.អ.ស.ក រៀបចំ អោយមានបណ្តាញកុមារអ្នកតស៊ូមតិនៅថ្នាក់ជាតិក្នុងក្របខ័ណ្ឌការងារអង្គការមិនមែនរដ្ឋាភិ-

តទៅទំព័រទី៨

តមកពីទំព័រទី៧

បាល ដែលក្នុងនោះមានតំណាងកុមារមកពី១១ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមកុមារទាំងនេះបានជួបជជែកពិភាក្សាអំពីស្ថានភាពរបស់កុមារនៅតាមសហគមន៍របស់ពួកគេផ្ទាល់យ៉ាងទៀងទាត់ ហើយពួកគេ បានចូលរួមចែករំលែកនូវទស្សនៈស្តីពីស្ថានភាពរបស់កុមារ និងអនុសាសន៍ទៅកាន់រដ្ឋាភិបាលនៅក្នុងវេទិកាកុមារ ពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា និងចូលរួមធ្វើការពិនិត្យឡើងវិញ លើការអនុវត្តពិភពលោកសមស្របសំរាប់កុមារ និងគោលដៅអភិវឌ្ឍន៍សហសវត្សក្នុងសន្និសិទ្ធកុមារនៃតំបន់អាស៊ីអាគ្នេយ៍ (ប្រាំបួនប្រទេសចូលរួម) នៅប្រទេសហ្វីលីពីន។ គ.អ.ស.ក កំពុងរៀបចំ របាយការណ៍បន្ថែមស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារនៅកម្ពុជាដើម្បីដាក់ជូនអង្គការសហប្រជាជាតិ។ល។

លោក **Johan Norqvist** តំណាងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែតមានចំណាប់អារម្មណ៍សំដែងនូវ ការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ គ.អ.ស.ក ក្នុងការលើកកំពស់ ការអនុវត្តសិទ្ធិកុមារក្នុងប្រទេសកម្ពុជា ជាពិសេសលើកកំពស់ ការចូលរួមរបស់កុមារទាំងនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ។

នៅព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៧ ក្រុមប្រតិភូបានចុះជួបសំណេះសំណាលជាមួយក្លឹបកុមាររបស់អង្គការលីកាដូនៅសាលាស្រុកមុខកំពូល ខេត្តកណ្តាល ដែលក្លឹបនេះជាសមាជិកមួយនៃបណ្តាញកុមារអ្នកតស៊ូមតិ។

## សិក្ខាសាលាស្តីពីការរៀបចំកម្មវិធីដោយផ្អែកលើសិទ្ធិជាមូលដ្ឋានរបស់កុមារ

គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក) បានរៀបចំសិក្ខាសាលា ស្តីពីការរៀបចំកម្មវិធីដោយផ្អែកលើសិទ្ធិជាមូលដ្ឋានរបស់កុមារ(Child Rights Programming) កាលពី ថ្ងៃទី ០៦ ខែមីនា ឆ្នាំ ២០០៧ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ៤០រូប មកពីអង្គការជាសមាជិក និង បុគ្គលិក គ.អ.ស.ក។

លោក ស៊ុំ ចំរុង អគ្គលេខាធិការ គ.អ.ស.ក មានប្រសាសន៍ថា សិក្ខាសាលានេះរៀបចំឡើង ក្នុងគោលបំណងដើម្បីចែករំលែកចំណេះដឹងអំពីការរៀបចំកម្មវិធីដោយផ្អែកលើសិទ្ធិជាមូលដ្ឋានរបស់កុមារ ក្នុងចំណោមអង្គការជាសមាជិក។ លោកបន្តទៀតថា វាគ្មិនសំខាន់ដែលត្រូវបានអញ្ជើញអោយចូលរួម សម្របសម្រួលសិក្ខាសាលាក្នុងថ្ងៃនេះ គឺលោកស្រី ខាត់ ទីឯករិសុទ្ធ ជាប្រធានកម្មវិធីនៃអង្គការន័រវេស៊្សសង្គ្រោះ កុមារ។

ឆ្លៀតក្នុងឱកាសនោះ លោក ស៊ុំ ចំរុង តាងនាម គ.អ.ស.ក និង សិក្ខាកាមទាំងអស់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអង្គការន័រវេស៊្សសង្គ្រោះកុមារ ដែលបានឧបត្ថម្ភទាំងថវិកា និងធនធានមនុស្សក្នុងការចែករំលែកនូវចំណេះដឹងលើប្រធានបទនេះដល់អង្គការជាសមាជិករបស់ គ.អ.ស.ក។



លោកស្រី ខាត់ ទីឯករិសុទ្ធ ណែនាំសិក្ខាកាមអោយស្គាល់គ្នា

# សេចក្ដីថ្លែងការណ៍ស្ដីពីស្ថានភាពកុមារ

គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក) បានរៀបចំ អនុម័តកាលពី ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៧ ទៅលើសេចក្ដីថ្លែងការណ៍ស្ដីពីស្ថានភាពថ្មីៗរបស់កុមារនៅកម្ពុជា ដើម្បីចូលរួមចំណែកដល់ការរៀបចំវេទិកាសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍កម្ពុជា ដែលគ្រោងរៀបចំធ្វើឡើង នៅខែមិថុនាខាងមុខនេះ។ សេចក្ដីថ្លែងការណ៍នេះត្រូវបានរៀបចំឡើងក្រោមកិច្ចសហការជាមួយ វេទិកាអង្គការមិនមែនរដ្ឋាភិបាល និងសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យផ្សេងៗទៀតជាច្រើន។

វាជាឯកសារយោងមួយសំរាប់កិច្ចពិភាក្សាពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងសហគមន៍ផ្ដល់ជំនួយសំរាប់រដ្ឋាភិបាលកម្ពុជា ក្នុងការពិនិត្យមើលទៅលើការរីកចំរើនលើការអនុវត្តសិទ្ធិកុមារ បញ្ហាដែលកំពុងប្រឈម និងអនុសាសន៍នានាដែលរាជរដ្ឋាភិបាលគួរតែចាត់វិធានការអោយមានប្រសិទ្ធិភាពដើម្បីធ្វើអោយប្រសើរឡើងនូវស្ថានភាពរបស់ កុមារនៅ កម្ពុជា។

ខាងក្រោមនេះគឺជាខ្លឹមសារនៃអនុសាសន៍ដែលមាន នៅក្នុងសេចក្ដីថ្លែងការណ៍ឆ្នាំ២០០៧:

## ១- ការអនុវត្តន៍ និងការតាមដានការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារគប្បី :

-ជាស្ថាប័នមួយដែលមានឧបនាយករដ្ឋមន្ត្រីជាប្រធាន ឬអគ្គលេខាធិការមានឋានៈខ្ពស់ជាងបច្ចុប្បន្ន

-រៀបចំបណ្ដាញការងាររបស់ខ្លួនរហូតដល់ខេត្ត-ក្រុង និងស្រុក-ខ័ណ្ឌ

-មានបុគ្គលិក និងមន្ត្រីផ្ទាល់របស់អង្គភាព សំរាប់ដំណើរការ ការងារ

-ទទួលការបង្កើនធនធាន ទាំងធនធានមនុស្ស និងថវិកា

-បង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មាន ដើម្បីតាមដានការអនុវត្តន៍ អនុសញ្ញាស្ដីពីសិទ្ធិកុមារ

## ២- គ្រឿងញៀន

រាជរដ្ឋាភិបាលគួរតែ:

-រឹតបន្ដឹងការអនុវត្តច្បាប់ ដោយបង្ក្រាបសកម្មភាពផលិត ជួញដូរ និងបណ្ដាញចែកចាយគ្រឿងញៀន អោយមានប្រសិទ្ធិភាព។

-បង្កើនការអប់រំផ្សព្វផ្សាយ អំពីផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន និងការប្រព្រឹត្តបទល្មើស ដល់ប្រជាជនគ្រប់មជ្ឈដ្ឋាន។

-បង្កើនថវិកា និងធនធានមនុស្សដែលមានជំនាញច្បាស់លាស់ក្នុងការព្យាបាលដល់ជនរងគ្រោះដោយសារគ្រឿងញៀន។

-បង្កើនមណ្ឌលស្ដារនីតិសម្បទា និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ អោយបានច្រើនកន្លែង ដោយមិនគិតថ្លៃ។

-បង្កើតកម្មវិធីសមាហរណកម្មដល់អ្នកដែលស្ដារនីតិសម្បទារួចហើយ ទៅកាន់គ្រួសារ និងសហគមន៍វិញ។

## ៣- ហ៊ីវ/អេដស៍

រាជរដ្ឋាភិបាលគួរតែ:

-បន្តបង្កើនការផ្ដល់ថ្នាំប្រឆាំងមេរោគអេដស៍ ដោយឥតបង់ថ្លៃដល់ប្រជាពលរដ្ឋ

-បង្កើតកម្មវិធីទ្រទ្រង់ដល់កុមារកំព្រាដោយសារ ឪពុកម្ដាយស្លាប់ដោយជម្ងឺអេដស៍

-លើកកំពស់ការជួយឧបត្ថម្ភរបស់សហគមន៍ ដល់កុមារកំព្រានិងលុបបំបាត់ភាពរើសអើងចំពោះកុមារកំព្រាដោយសារ

តទៅទំព័រទី១០

តពីទំព័រទី៩

ឪពុកម្តាយស្លាប់ដោយជម្ងឺអេដស៍ និងកុមារដែលផ្ទុកមេរោគអេដស៍។

## ៤- ការរំលោភ ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

រាជរដ្ឋាភិបាលគួរតែ:

-អនុម័តអោយបានឆាប់រហ័សនូវផែនការជាតិ៥ឆ្នាំលើកទី២ ប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ច ផ្លូវភេទលើកុមារ

-ជំរុញការអនុម័តច្បាប់ថ្មីស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្សអោយបានឆាប់រហ័ស។

-ពង្រឹងការអនុវត្តន៍ច្បាប់ព្រហ្មទណ្ឌក្នុងការផ្តន្ទាទោសជនល្មើសរំលោភនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

-បំបាត់ការផ្សព្វផ្សាយទស្សនាវដ្តី កាសែតវីដេអូអាសអាភាស ដោយធ្វើការពង្រឹងការអនុវត្តន៍ ប្រកាសអន្តរក្រសួងលេខ១៤ស.ស.រ ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការធ្វើពាណិជ្ជកម្មលើ រូបភាពអាសអាភាស ។

-ពង្រឹងការអប់រំពីសីលធម៌សង្គមនិងបង្កើតវិធានការទប់ស្កាត់នៅតាមសហគមន៍ តាមរយៈការចូលរួមរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ប៉ូលីស មេភូមិ ព្រះសង្ឃ និងអ្នកដែលមានឥទ្ធិពលក្នុងសហគមន៍។

## ៥- ពលកម្មកុមារ

រាជរដ្ឋាភិបាលគួរតែ:

-អនុម័តអោយបានឆាប់រហ័សនូវផែនការជាតិស្តីពីការប្រឆាំងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

-ការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ នៅពេលដែលដកយកកុមារចេញពីស្ថានភាពពលកម្មធ្ងន់ធ្ងរ ត្រូវជាជំនាញដែលកុមារអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ ហើយការវិភាគអំពីតំរូវការទីផ្សារគួរ តែធ្វើឡើងជាមុន។

-បង្កលក្ខណៈអោយកុមារដែលកំពុងបំរើការងារនៅតាមផ្ទះ មានឱកាសទទួលបាននូវការអប់រំ ដោយបង្កើតកម្មវិធីអប់រំម្ចាស់ផ្ទះ ដែលយកកុមារមកបំរើការងារ។

-បើកយុទ្ធនាការថ្នាក់ជាតិមួយដើម្បីអោយមហាជនចាប់អារម្មណ៍ លើបញ្ហាកុមារបំរើការងារតាមផ្ទះ។

-បង្កើតនូវយន្តការនៅក៏រិតសហគមន៍ដើម្បីត្រួតពិនិត្យការរំលោភបំពានធ្ងន់ធ្ងរ។

## ៦- ប្រព័ន្ធយុត្តិធម៌សំរាប់កុមារ

រាជរដ្ឋាភិបាលគួរតែ:

-ជំរុញអោយបានរហ័សលើការអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលកំពុងស្ថិតនៅក្នុងសេចក្តីព្រាងនៅឡើយ ។

-បំបែកកុមារដែលត្រូវជាប់ឃុំឃាំងជាបន្ទាន់ ចេញពីមនុស្សពេញវ័យ និងធានាអោយមានកម្មវិធីអប់រំ និងស្តារនីតិសម្បទាដល់កុមារដែលជាប់ពន្ធនាគារ ។

-ជំរុញអោយបានរហ័សចំពោះការបង្កើតតុលាការសំរាប់រឿងក្តីកុមារ ដាច់ដោយឡែកពីតុលាការសំរាប់មនុស្សពេញវ័យ។

-បង្កើនចំនួនចៅក្រម និងមេធាវីដែលមានជំនាញ សំរាប់ដោះស្រាយរឿងក្តីកុមារ។



ការជជែកពិភាក្សាលើពង្រាងសេចក្តីថ្លែងការណ៍របស់សមាជិក គ. អ. ស. ក

*តមកពីទំព័រទី១*

ទោសដល់ក្រោមអប្បបរមា ឬព្យួរទោសគុក សំរាប់ការផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយ។ មុនពេលច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋចូលជាធរមាននៅឆ្នាំ២០០២ ចៅក្រមអនុវត្តតាមបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល " ច្បាប់អ៊ុនតាក់ " ក្នុងការថ្លឹងថ្លែងពីស្ថានសំរាល ដើម្បីបន្ធូរបន្ថយទោស រហូតដល់ក្រោមអប្បបរមានៃទោសដែលកំណត់ ដោយច្បាប់អនុលោមតាមមាត្រា៦៨។ គេសង្កេតឃើញថា មាត្រា៦៨ នៃច្បាប់អ៊ុនតាក់ បានអនុវត្តស្របជាមួយមាត្រា៣៧-ខ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារដែលចែងថា "ការដាក់ពន្ធនាគារចំពោះកុមារ...ត្រូវបានប្រើតែសំរាប់ជាវិធានការចុងក្រោយ ហើយការដាក់ពន្ធនាគារនេះសំរាប់តែក្នុងរយៈពេលដ៏ខ្លីសមស្របមួយប៉ុណ្ណោះ"។ មាត្រា៣៧-ខ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារគូសបញ្ជាក់យ៉ាងច្បាស់ថា ចៅក្រមត្រូវបានអនុញ្ញាតអោយប្រើអំណាចឆន្ទានុសិទ្ធិ ដើម្បីកំណត់ទោសក្រោមអប្បបរមា ដែលមានចែងនៅក្នុងច្បាប់ រួមទាំងលទ្ធភាពនៃការផ្តន្ទាទោសមិនដាក់ពន្ធនាគារទៀតផង តែប្រការនេះ ត្រូវបានលប់ចោលដោយមាត្រា៨ និង៩ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ពីលទ្ធភាពរបស់ចៅក្រម ដែលកាលពីមុនត្រូវបានអនុញ្ញាតដោយមាត្រា៦៨ នៃច្បាប់អ៊ុនតាក់ ដើម្បីកំណត់ទោសមួយដែលស្រាលជាង ឬការផ្តន្ទាទោសមិនដាក់ពន្ធនាគារ ក្នុងរឿងក្តីកុមារ ដែលត្រូវផ្តន្ទាទោសពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ។

ជាផលវិបាក ច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋបង្កើត ការមើលឃើញជាបឋម អំពីការរំលោភមាត្រា ៣៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

ចាប់តាំងពីច្បាប់នេះចូលជាធរមានមក ចៅក្រមត្រូវបានតម្រូវអោយកំណត់ទោសដាក់ពន្ធនាគារ យ៉ាងធ្ងន់ធ្ងរដល់កុមារ ដែលពួកគេសមនឹងទទួលត្រឹមតែការផ្តន្ទាទោសមិនដាក់ពន្ធនាគារនោះ។

ប្រទេសកម្ពុជាបានផ្តល់ សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ កាលពីថ្ងៃទី១៥ ខែ តុលា ឆ្នាំ១៩៩២ ហេតុនេះហើយ ប្រទេសកម្ពុជា ត្រូវរ៉ាប់រងអនុវត្តតាមគ្រប់ទិដ្ឋភាពទាំងអស់នៃអនុសញ្ញានេះ។

មាត្រា៣១ នៃរដ្ឋធម្មនុញ្ញចែងថា " ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា និងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ។ "

មាត្រា៤៨ នៃរដ្ឋធម្មនុញ្ញចែងថា "រដ្ឋធានារក្សា ការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពី សិទ្ធិកុមារ..."។

អានុភាពនៃមាត្រា៣១ និង៤៨ នៃរដ្ឋធម្មនុញ្ញ គឺដើម្បីដាក់បញ្ចូលបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញាស្តីពីសិទ្ធិកុមារដោយផ្ទាល់ទៅក្នុងរដ្ឋធម្មនុញ្ញ ហើយជាផលវិបាក បញ្ញត្តិច្បាប់ណាក៏ដោយដែលរំលោភ បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ក៏រំលោភរដ្ឋធម្មនុញ្ញផងដែរ ហើយបញ្ញត្តិច្បាប់ទាំងនោះគឺអធម្មនុញ្ញភាព។ ដោយសារមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ បំពានតំរូវការទាំងឡាយដែលមានចែងនៅក្នុងមាត្រា៣៧-ខ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ច្បាប់នេះក៏រំលោភបំពានមាត្រា៣១ និងមាត្រា៤៨ នៃរដ្ឋធម្មនុញ្ញដែរ។

យោងតាមមាត្រា១៣៦-ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៥ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សា

*តទៅទំព័រទី១២*

**តមកពីទំព័រទី១១**

ធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញមានកាតព្វកិច្ច ការពារការគោរពរដ្ឋធម្មនុញ្ញ និងបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់នានាដែលបានអនុម័តដោយ រដ្ឋសភា និងព្រឹទ្ធសភាដែលបានពិនិត្យចប់សព្វគ្រប់ហើយ ។

យោងតាមមាត្រា១៤២ នៃរដ្ឋធម្មនុញ្ញ បទបញ្ញត្តិទាំងឡាយនៃមាត្រាណាមួយ ដែលត្រូវបានសំរេចដោយក្រុមប្រឹក្សាធម្មនុញ្ញ ថាអធម្មនុញ្ញភាព មិនត្រូវប្រកាសអោយប្រើឬអនុវត្តឡើយ ហើយតាមរយៈមាត្រា២០ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសំរេចថាបទបញ្ញត្តិណាមួយនៃច្បាប់ផ្ទុយនឹងរដ្ឋធម្មនុញ្ញ បទបញ្ញត្តិអធម្មនុញ្ញនេះ មិនត្រូវយកមកអនុវត្តទេ ប្រសិនបើបទបញ្ញត្តិទាំងនេះអាចបំបែកចេញពីអត្ថបទច្បាប់ទាំងមូល បើពុំនោះទេ អត្ថបទច្បាប់ទាំងមូលមិនត្រូវយកមកអនុវត្តទេ ប្រសិនបើបទបញ្ញត្តិទាំងនោះមិនអាចបំបែកចេញបាន ។

យោងតាមមាត្រា១៥០នៃរដ្ឋធម្មនុញ្ញ រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ហើយច្បាប់ទាំងអស់ និងសេចក្តីសំរេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

យោងតាមមាត្រា១៤១នៃរដ្ឋធម្មនុញ្ញ និងមាត្រា១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បន្ទាប់ពីច្បាប់មួយត្រូវបានប្រកាសអោយប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភា ១/៤ សមាជិករដ្ឋសភា ១/១០ ឬតុលាការ អាចសុំអោយក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។

អង្គប្រជុំបានជជែកពិភាក្សាផងដែរទៅលើវិធីសាស្ត្រក្នុងការទូលថ្វាយ និងដាក់ញត្តិនេះជូនទៅ ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងសមាជិកទាំងអស់ ប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់ ព្រមទាំងកំណត់នូវកាលបរិច្ឆេទក្នុងការប្រជុំលើកក្រោយទៀត ដើម្បីកែលំអរបន្ថែមទៅលើញត្តិ និងវិធីសាស្ត្រនៃការចុះហត្ថលេខារបស់តំណាងអង្គការដែលចូលរួមគាំទ្រ។ អង្គប្រជុំបានសំរេចថានឹងរៀបចំអោយមានការចូលរួមរបស់កុមារក្នុងការគាំទ្រទៅលើញត្តិនេះផងដែរ ។

---

**តមកពីទំព័រទី៥**

-ខ្វះសាលាមត្តេយ្យ

*អនុសាសន៍* :

-បន្ថែមគ្រូអោយបានគ្រប់គ្រាន់ និងបែងចែកគ្រូអោយត្រូវតាមមុខជំនាញ

-ពង្រឹងសមត្ថភាពគ្រូបន្ថែម

-សូមបន្ថែមប្រាក់ខែដល់គ្រូ ហើយបើកប្រាក់ខែអោយទៀងទាត់

-សំណូមពរដល់គ្រូបង្រៀនមេត្តាបញ្ឈប់ការប្រមូលប្រាក់ពីសិស្សពេលម៉ោងសិក្សា

-សំណូមពរកុំអោយបើកបង្រៀនគួរនៅពេលម៉ោងសិក្សារដ្ឋ និងម៉ោងចេញលេង

-រដ្ឋាភិបាលគួរចាត់វិធានការលុបបំបាត់ ការរើសអើងគ្រប់រូបភាពចំពោះសិស្ស

-ពង្រឹងការអនុវត្តន៍អោយបានត្រឹមត្រូវ នូវគោលការណ៍មិនប្រើអំពើហិង្សាលើសិស្ស

-លុបបំបាត់ការសមគំនិតរវាងនាយក និងគ្រូក្នុងការគេងប្រវ័ញ្ចលើសិស្ស

**តទៅទំព័រទី១៣**

តមកពីទំព័រទី១២

-បង្កើតក្រុមស៊ើបអង្កេតលើសកម្មភាពរបស់គ្រូនាយក

-បង្កើតក្រុមការងារដើម្បីតាមដាន និងត្រួតពិនិត្យការអនុវត្តការងាររបស់សាលានីមួយៗ

-បន្ថែមអោយមាននូវសំភារៈសិក្សាដូចជាតុ ទូ កៅអី ឧបករណ៍ពិសោធន៍ សំភារៈកីឡា និង កំសាន្ត អោយបានគ្រប់គ្រាន់

-សាងសង់អាគារសិក្សាគ្រប់កំរិតអោយបានគ្រប់គ្រាន់

-ដោះស្រាយមធ្យោបាយធ្វើដំណើរដល់សិស្ស និងគ្រូ

-បន្ថែមអាហារូបករណ៍ដល់សិស្ស

-សាងសង់អាគារស្នាក់នៅសំរាប់សិស្សមកពីឆ្ងាយ

-ផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការសិក្សាអោយបានទូលំទូលាយ ដើម្បីកាត់បន្ថយការបោះបង់ការសិក្សា

-អោយមានកិច្ចសហប្រតិបត្តិការ ពីថ្នាក់មូលដ្ឋានដើម្បីតាមដានសង្កេតពិនិត្យ និងជំរុញអោយសិស្ស ដែលបោះបង់ការសិក្សាអោយទទួលយកការសិក្សាឡើងវិញ

-ពង្រីកសាលាកុមារមេត្រីអោយបានគ្រប់ខេត្ត-ក្រុង

-បង្កើតថ្នាក់អប់រំក្រៅប្រព័ន្ធ

**២-<u>ក្រុមទី ២ : បរិយាកាសគ្រួសារ និងកិច្ចថែទាំជំនួស សុខភាពមូលដ្ឋាន និងសុខុមាលភាព</u>**

**<u>បរិយាកាសគ្រួសារ និងការថែទាំជំនួស</u> :**

*<u>អនុសាសន៍</u>* :

-សូមពង្រឹងនូវការអនុវត្តច្បាប់សុំកូន

-គួរតែបង្កើតមណ្ឌលកុមារកំព្រានៅកន្លែងដែលមានកុមារកំព្រាច្រើន

-សូមអោយមានប្រាក់ឧបត្ថម្ភដល់កុមារកំព្រាផ្ទាល់

-សូមអោយរាជរដ្ឋាភិបាលប្រមូលក្មេងអនាថា ក្មេងកំព្រាបិតការ សុំទាន មកនៅក្នុងមណ្ឌល

-បង្កើតបណ្តាញគាំពារកុមារនៅតំបន់ដាច់ស្រយាល

-សូមផ្តល់ភាពកក់ក្តៅ និងតំរូវការដល់កុមារកំព្រាទាំងនោះ

-តាមដានត្រួតពិនិត្យរាល់ការសុំកូនទៅអន្តរប្រទេសតាមរយៈស្ថានទូត

-ផ្តល់ការការពារកុមារក្នុងមណ្ឌល និងសុវត្ថិភាពជុំវិញមណ្ឌល

-បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងភាសាបរទេសបន្ថែមដល់កុមារកំព្រា

-សូមបន្ថែមថ្នាក់វិជ្ជាជីវៈនៅតាមសមាគមន៍ សំរាប់យុវជនឬកុមារដែលបោះបង់ចោលការសិក្សា

**<u>សុខភាពមូលដ្ឋាន និងសុខុមាលភាព</u> :**

-បង្កើតមណ្ឌលសុខភាពតាមភូមិ-ឃុំ

-បង្កើនវេជ្ជបណ្ឌិតជំនាញ គិលានុបដ្ឋាយិកា និងសម្ភារៈគ្រប់គ្រាន់សំរាប់ព្យាបាលនៅតាមភូមិ-ឃុំ

-ពង្រឹងការទទួលខុសត្រូវនូវតួនាទីរបស់វេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកាចំពោះប្រជាជននៅតាមមូលដ្ឋាន

-ផ្តល់ថ្នាំបង្ការដល់ភូមិដាច់ស្រយាល និងផ្សព្វផ្សាយអោយបានទូលំទូលាយពីផលប្រយោជន៍នៃការចាក់ថ្នាំបង្ការ

-បន្ថែមភាពកក់ក្តៅដល់កុមារពិការ និងកុមារកើតអេដស៍

**៣-<u>ក្រុមទី៣ និង៤ : វិធានការការពារពិសេស</u>**

**<u>កុមារនិងគ្រឿងញៀន</u> :**

-បង្កើតមជ្ឈមណ្ឌលអប់រំគ្រឿងញៀនអោយបានច្រើន ជាពិសេសនៅតាមតំបន់ដាច់ស្រយាល

-បង្កើនជំនាញវិជ្ជាជីវៈដល់កុមារចេញពីនីតិសម្បទា (ដាច់ចេញពីគ្រឿងញៀន)

-ពង្រឹងច្បាប់គ្រឿងញៀន និងចូលរួមសហការទាំងអស់គ្នា

-មានការផ្សព្វផ្សាយតាមភូមិស្រុកពីផលវិបាកនៃគ្រឿងញៀនដល់ប្រជាពលរដ្ឋតាមសហគមន៍

តទៅទំព័រទី១៤

តមកពីទំព័រទី១៣

-បង្កើតក្រុមស៊ើបអង្កេតពីការជួញដូរគ្រឿងញៀន

-ប្រមូលកុមារញៀនថ្នាំទៅដាក់ក្នុងមណ្ឌល

**កុមារបំរើការងារតាមផ្ទះ :**

-បង្កើតការអនុវត្តអោយបានច្រើន

-បង្កើតមណ្ឌលផ្តល់ជំនាញផ្សេងៗ និងរកទីផ្សារ រកប្រាក់ចំណូល និងអាចអោយកុមារមានពេលរៀនសូត្រ ជាពិសេសកុមារក្រីក្រ ជួយផ្តល់ប្រាក់តណាទានដើម្បីរកស៊ី

-ផ្សព្វផ្សាយដល់ប្រជាជនពីផលប៉ះពាល់នៃពលកម្មកុមារ នៅតាមទីជនបទដាច់ស្រយាល

-កំណត់ម៉ោងធ្វើការរបស់កុមារទៅតាមទំហំការងារ

-ដាក់ពិន័យដល់ក្រុមហ៊ុន សហគ្រាស ឬជនដែលទទួលអោយកុមារធ្វើការងារធ្ងន់ៗប៉ះពាល់ដល់សុខភាពកុមារ

-ឪពុកម្តាយមិនត្រូវអោយកុមារចាកចេញពីគ្រួសារទៅរកប្រាក់កំរៃ

-ប្រមូលកុមារអន្តោប្រវេសន៍ខុសច្បាប់ ត្រលប់ទៅស្រុកកំណើតវិញ (កុមារអនាថា កុមារសុំទានតាមព្រំដែន...)

**អំពើហិង្សាលើកុមារ (ក្នុងក្រុមគ្រួសារ) :**

-ផ្សព្វផ្សាយពីច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះ

-ចុះធ្វើអន្តរាគមន៍ពីអាជ្ញាធរដែនដី និងអ្នកជិតខាង ដល់គ្រួសារដែលមានអំពើហិង្សា

-ធ្វើការណែនាំដល់ឪពុកម្តាយដែលប្រើអំពើហិង្សាលើកុមារ

-ចុះពន្យល់ណែនាំកុមារអោយស្គាល់ពីអំពើហិង្សា

**អំពើហិង្សាលើកុមារ (ក្នុងសាលា) :**

-មិនត្រូវប្រើអំពើហិង្សាក្នុងការអប់រំដល់កុមារ

*សូមរដ្ឋាភិបាលបញ្ចូលសមិទ្ធិផលស្តីពីអំពើហិង្សាលើកុមារចូលក្នុងរបាយការណ៍ជាតិ*

**កុមារពិការ :**

*ចំណុចខ្វះខាត* :

-បង្កើនមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់កុមារ

-ផ្តល់ការងារដល់កុមារពិការ (ចាប់ពីអាយុ១៥-១៧ឆ្នាំ)

-គួរតែផ្តល់ឱកាសអោយកុមារពិការរាល់សកម្មភាពសង្គមដែលទាក់ទងនឹងផលប្រយោជន៍កុមារ

*សូមអោយរដ្ឋាភិបាលបញ្ចូលសមិទ្ធិផលស្តីពីកុមារពិការចូលក្នុងរបាយការណ៍ជាតិ*

**កុមារទំនាស់នឹងច្បាប់ :**

*ចំណុចខ្វះខាត* :

-ខ្វះខាតមេធាវីដែលមានជំនាញ

-ប្រជាជន និងអាជ្ញាធរខ្វះខាតការយល់ដឹងពីសិទ្ធិកុមារដែលទំនាស់នឹងច្បាប់

-ច្បាប់ការពារអនីតិជនដែលទំនាស់នឹងច្បាប់ មិនទាន់បានអនុម័ត

-ខ្វះខាតមណ្ឌលកែប្រែកុមារដែលប្រព្រឹត្តិបទល្មើសព្រមទាំងអ្នកជំនាញ

-ខ្វះខាតចៅក្រមជំនាញសំរាប់រឿងក្តីកុមារ

*អនុសាសន៍* :

-រក្សាកិត្តិយសកុមារដែលប្រព្រឹត្តិល្មើសច្បាប់

-សូមអោយមានមេធាវីដែលមានជំនាញសំរាប់ការពារកុមារ

-បង្កើនការអប់រំដល់ប្រជាជន អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធនឹងកុមារ

-ជំរុញអោយការអនុម័តច្បាប់យុត្តិធមិអនីតិជន អោយបានឆាប់រហ័ស

-ពង្រឹងការអនុវត្តច្បាប់ និងកាត់បន្ថយអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ

តទៅទំព័រទី១៥

តមកពីទំព័រទី១៤

-សូមអោយមានការដាក់ដោយឡែករវាងកុមារនិងមនុស្សពេញវ័យ

-ផ្តល់ជំនាញវិជ្ជាជីវៈដល់កុមារអំឡុងពេលនៅក្នុងមណ្ឌលកែប្រែ

-សូមអោយមានអ្នកជំនាញផ្តល់ប្រឹក្សា និងលើកទឹកចិត្តដល់កុមារ

-សូមអោយមានការបង្វែរកុមារដែលប្រព្រឹត្តិបទល្មើសតូចតាច ឬមជ្ឈឹមចេញពីប្រព័ន្ធយុត្តិធមិ

**ការជួញដូរកុមារ :**

*ចំណុចខ្វះខាត* :

-ការផ្សព្វផ្សាយមិនទាន់មានភាពទូលំទូលាយ

-ការអនុវត្តច្បាប់មានភាពធូររលុង (សៀវភៅ ឬវីដេអូអាសអាភាស) ជនល្មើសដែលមានអំណាច និងទឹកប្រាក់ នៅតែរួចខ្លួនដដែល

-កង្វះការយល់ដឹងអំពីបញ្ហាចំណាកស្រុកដោយសុវត្ថិភាព

-ទាក់ទងនឹងចំណេះដឹងអំពីការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ មិនទាន់ជ្រាបចូលក្នុងប្រព័ន្ធអប់រំ

-សង្គមស៊ីវិល ប្រជាពលរដ្ឋ រដ្ឋាភិបាល មិនទាន់បានយកចិត្តទុកដាក់ចំពោះការរំលោភបំពានផ្លូវភេទលើកុមារា

-មណ្ឌលសំរាប់ជនរងគ្រោះ មាននៅតែតំបន់ទីប្រជុំជនមួយចំនួន

-កង្វះជំនាញក្នុងការផ្តល់ប្រឹក្សាដល់ជនរងគ្រោះ

*អនុសាសន៍* :

-បង្កើនការផ្សព្វផ្សាយអំពីការជួញដូរ និងការរំលោភផ្លូវភេទដល់ប្រជាពលរដ្ឋ អោយមានការយល់ដឹងកាន់តែទូលំទូលាយគ្រប់តំបន់

-សូមបញ្ឈប់ការនាំចូលវីស៊ីដេអាសអាភាស

-ពង្រឹកអោយមានការអនុវត្តច្បាប់អោយតឹងរឹងចំពោះអ្នកប្រព្រឹត្តិបទល្មើសរំលោភបំពានផ្លូវភេទលើកុមារ (ចំពោះអ្នកមានអំណាច និងទឹកប្រាក់)

-សូមអោយមានការបង្កើតបណ្តាញកុមារប្រឆាំងការជួញដូរផ្លូវភេទ និងរំលោភ ទូទាំងខេត្ត-ក្រុង

-ផ្សព្វផ្សាយអោយកាន់តែទូលំទូលាយចំពោះការជួញដូរ និងការរំលោភផ្លូវភេទលើកុមារា

-ចង់អោយមានការិយាល័យប្រយុទ្ធប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ នៅតំបន់ដែលសំបូរការរំលោភផ្លូវភេទ និងការជួញដូរផ្លូវភេទ

-បង្កើតមជ្ឈមណ្ឌលសំរាប់ជនរងគ្រោះអោយបានគ្រប់តំបន់

-សូមអោយមានអ្នកជំនាញពិតប្រាកដផ្តល់ការប្រឹក្សា

**កុមារអនាថា :**

*ចំណុចខ្វះខាត* :

-ខ្វះខាតការស្រាវជ្រាវពីកំរិត (ចំនួន) កុមារអនាថា និងកុមារកំព្រា

*អនុសាសន៍* :

-សូមបញ្ជាក់អោយច្បាស់ពីសមិទ្ធិផលអំពីកុមារអនាថា និងកុមារកំព្រាដែលរដ្ឋាភិបាលបានធ្វើ

-ពង្រីកការអប់រំ និងផ្សព្វផ្សាយដល់កុមារអនាថា



ការឡើងបកស្រាយលើលទ្ធផលនៃការពិភាក្សាតាមក្រុមនីមួយៗ

## គណៈកម្មការពិនិត្យ

- លោក មាស សំណាង ប្រធាន គ. អ. ស. ក
- លោក ម៉ិច សុខា អនុប្រធាន គ. អ. ស. ក
- កញ្ញា លី សុទ្ធារី លេខាធិការ គ. អ. ស. ក
- លោកស្រី ថូ ថារី ហិរញ្ញិក គ. អ. ស. ក
- លោក ព្រុំ ធី សមាជិក គ. អ. ស. ក
- លោក ស៊ុំ ចំរុង អគ្គលេខាធិការ គ. អ. ស. ក

## យកព័ត៌មាន និពន្ធ និង ក្រាហ្វិកកុំព្យូទ័រ

- លោក ឃុន ពិសី អ្នកគ្រប់គ្រងព័ត៌មាន
- កញ្ញា សាយ សុភា មន្ត្រីព័ត៌មានវិទ្យា
- លោក ព្រុំ វិចិត្រ មន្ត្រីធនធានឯកសារសិទ្ធិកុមារ

## បោះពុម្ពដោយ

គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ
អាសយដ្ឋានទំនាក់ទំនង
ផ្ទះលេខ៨A ផ្លូវ១៣៨ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទៈ (៨៥៥)២៣ ៨៨២ ៤១២
អ៊ីមែលៈ info@ngocrc.org
គេហទំព័រៈ www.ngocrc.org

## ឧបត្ថម្ភដោយ